ថ្នាំសំរាប់
ជំងឺរបេង

Developed by the
Minnesota Department of Health,
Tuberculosis Prevention and Control Program
January 1997 phone: (612) 676-5414

This is one in a series of four patient education pamphlets that addresses TB to be used in various clinical situations.

Medicine for Tuberculosis Disease, Cambodian

ថ្នាំសំរាប់ ជំងឺរបេង

មន្ទីរព្យាបាលសុខភាពរបស់អ្នក បានចេញសំបុត្រឱ្យទិញថ្នាំសំរាប់សម្លាប់មេរោគរបេងដែលនៅក្នុងខ្លួនអ្នក។

ជំងឺរបេងអាចព្យាបាលឱ្យជា ដោយការលេបថ្នាំសម្លាប់មេរោគរបេង ប៉ុន្តែមេរោគរបេងនេះមានកម្លាំងណាស់។ អ្នកត្រូវតែលេបថ្នាំជាច្រើនខែ ដើម្បីឱ្យឃើញច្បាស់ថា មេរោគរបេងនោះស្លាប់អស់។ អ្នកត្រូវតែលេបថ្នាំទៅតាមមន្ទីរព្យាបាលរបស់អ្នក ដែលបានចេញឱ្យប្រើ។

ជំងឺរបេងអាចព្យាបាលឱ្យជាដាច់ស្រឡះ

អ្នកនឹងប្រហែលចាប់ផ្តើមដឹងថាស្រួលខ្លួន ក្នុងរយ:២ ទៅពាអាទិត្យ ប៉ុន្តែអ្នកត្រូវតែបន្តការលែបថ្នាំ ដើម្បីឱ្យជាដាច់ស្រឡះ។

បើអ្នកឈប់លេបថ្នាំរហ័សពេក មេរោគរបេងដែលនៅរស់នៅឡើយ អាចទៅជាមានកម្លាំងខ្លាំងជាងមុន។ អ្នកនឹងត្រូវប្រើថ្នាំខ្លាំងជាងមុន ដើម្បីសម្លាប់មេរោគដែលខ្លាំងៗទាំងនោះ។

សូមលេបថ្នាំរបស់អ្នកទាំងអស់!

ថ្នាំសំរាប់រោគរបេង ជាធម្មតាមិនដែលមានគ្រោះថ្នាក់ទេ ប៉ុន្តែជួនកាល វាអាចធ្វើឱ្យមានកើតរោគផ្សេងៗខ្លះដែរ។ បើអ្នកមានអាការរោគដូចខាងក្រោមនេះ សូមទូរស័ព្ទ ឬទៅជួបជាមួយមន្ទីរព្យាបាលសុខភាពអ្នកជាប្រញាប់:

- ពិសារអ្វីមិនបាន
- ក្អួត
- ឈឺពោះ
- ចង្អោរ
- ភ្នែកឬស្បែករបស់អ្នកឡើងពណ៌លឿង
- ការឈឺធៀបៗតាមម្រាមដៃឬម្រាមជើងរបស់អ្នក
- ការឈឺធៀបៗឬស្ពឹកនៅជុំវិញមាត់របស់អ្នក
- ស្រវាំងភ្នែកឬផ្លាស់ប្តូរការមើលឃើញរបស់អ្នក
- ហ៊ុងត្រចៀក
- ថ្លង់ ស្តាប់មិនឮ
- វិលមុខ
- ឈឺសន្លាក់ដៃជើង
- គ្រុនក្តៅលើសពីពាថ្ងៃ
- ចេញរមាស់លើស្បែក
- ចេញឈាមដោយស្រួលៗ
- មានស្នាមជាំដោយស្រួលៗ



មន្ទីរព្យាបាលសុខភាពរបស់អ្នក បានចេញសំបុត្រឱ្យទិញថ្នាំដែលបានគូសខាងក្រោមនេះ:

_____**Isoniazid (INH)**

_____**Rifampin***

_____**Pyrazinamide (PZA)**

_____**Ethambutol**

_____**Streptomycin**
(ថ្នាំស្ទ្រិបតូមីស៊ីនគឺជាថ្នាំចាក)

* អ្នកគួរតែប្រយ័ត្នផងដែរថា ខាងក្រោមនេះគឺរោគផ្សេងៗដែលកើតឡើងដោយសារថ្នាំ**Rifampin:**

- ទឹកនោម ទឹកមាត់ ឬទឹកភ្នែកអាចនឹងទៅជាពណ៌លឿងចាស់។ កញ្ចក់ពាក់និងភ្នែកអាចជាប់ប្រឡាក់ពណ៌នេះដែរ។
- ស្បែកអ្នកមិនអាចទ្រាំនិងកំដៅថ្ងៃបានទេ។ សូមប្រើប្រេងលាបការពារលើស្បែកកន្លែង ដែលត្រូវកំដៅថ្ងៃ។
- ថ្នាំលេបមិនឱ្យមានកូន និងរបស់ដាក់ផ្សាំក្នុងខ្លួន (implants) គឺវាត្រូវបន្ថយប្រសិទ្ធិភាពនៅពេលអ្នកលេបថ្នាំ **Rifampin** នេះ។ ស្រីដែលលេបថ្នាំ **Rifampin** គួរប្រើវិធីការពារកុំឱ្យមានកូន តាមរបៀបផ្សេងទៀត។



សូមប្រាប់មន្ទីរព្យាបាលរបស់អ្នក អំពីថ្នាំទាំងឡាយណាដែលអ្នកកំពុងលេបសព្វថ្ងៃនេះ។

សូមប្រាប់មន្ទីរព្យាបាលរបស់អ្នក បើអ្នកមានផ្ទៃពោះ ឬអ្នកបំបៅកូនដោយដោះ។

ថ្នាំសំរាប់រោគរបេងអាចទទួលបានដោយអ្នកមិនបាច់បង់ប្រាក់ឡើយ។ មន្ទីរព្យាបាលអ្នកអាចទាក់ទងជាមួយក្រសួងសុខាភិបាលរដ្ឋមិនីសូតាសំរាប់សុំថ្នាំនេះ (612/676-5414)។